គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

ភ្នំពេញ, ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង
## ស្តីអំពីវេទិកា
## "កំណែទម្រង់ការបោះឆ្នោត និងលំហរប្រជាធិបតេយ្យនៅកម្ពុជា"

គណៈកម្មការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ក្រោមកិច្ចសហការជាមួយបណ្តាអង្គការ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមានមូលដ្ឋាននៅក្នុងខេត្តមួយចំនួនដែល ខុមហ្វ្រែល នឹងរៀបចំវេទិកា មានកិត្តិយសសូមជម្រាបជូនដំណឹង និងគោរពអញ្ជើញដល់លោក លោកស្រី នាងកញ្ញា តំណាងសារព័ត៌មានជាតិ និងអន្តរជាតិ មេត្តាជ្រាបថា ខុមហ្វ្រែល នឹងរៀបចំវេទិកាស្តីអំពី *"កំណែទម្រង់ការបោះឆ្នោត និងលំហរប្រជាធិបតេយ្យនៅកម្ពុជា"* នៅក្នុងខេត្តចំនួន៤ ក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងកំឡុងខែមករានេះនៅ *ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តក្រចេះ និងខេត្តកំពង់ឆ្នាំង* ដោយមានការចូលរួមពី តំណាងគណបក្សនយោបាយ តំណាងគ.ជ.បខេត្ត អាជ្ញាធរ ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ។

វេទិកានេះរៀបចំឡើងក្នុងគោលបំណង ដើម្បីឲ្យភាគីដែលពាក់ព័ន្ធបានលើកឡើង និងជជែកពីបញ្ហាដែលទាក់ទងទៅនឹងការបោះឆ្នោត និងប្រជាធិបតេយ្យនៅកម្ពុជា ហើយស្វែងរកនូវអនុសាសន៍ គោលនយោបាយដែលបានពិភាក្សា ចែកជូនដល់អ្នកចូលរួម និងបញ្ជូនអនុសាសន៍ទាំងនោះទៅស្ថាប័នដែលពាក់ព័ន្ធក្នុងការដោះស្រាយ។

សេចក្តីជូនដំណឹងនេះ ចាត់ទុកជាការអញ្ជើញដល់លោក លោកស្រី អ្នកនាង កញ្ញា តំណាងសារព័ត៌មានជាតិ និងអន្តរជាតិ សូមចូលរួមយកព័ត៌មានតាមការគួរ។

សូមអរគុណ !

### *ទីកន្លែង និងកាលបរិច្ឆេទ រៀបចំវេទិកា*

| កាលបរិច្ឆេទ | ខេត្ត | ទីកន្លែង |
|---|---|---|
| ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៣ | កំពង់ចាម | សណ្ឋាគារ ភ្នំប្រុស |
| ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១៣ | កំពង់ធំ | ភោជនីយដ្ឋានម្លប់ស្វាយធំ |
| ថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៣ | ក្រចេះ | សណ្ឋាគារ លីជី |
| ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៣ | កំពង់ឆ្នាំង | សណ្ឋាគារ ទន្លេសាប |

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង* ៖

*១-លោក **សួន យុត្ថា** / មន្ត្រីតស៊ូមតិ និងច្បាប់ខុមហ្វ្រែល (០៩៧-៥៩-៨៧-២៦៥)*

ទស្សនៈវិស័យ ៖ ដើម្បីឲ្យការបោះឆ្នោតមានអត្ថន័យ ដែលប្រកបដោយលក្ខណៈប្រជាធិបតេយ្យ។
**Vision:** A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.**
**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org